ក

# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


៣០-៩-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៩១៣/៩៤៩ ស្តីពី ការបញ្ចប់មុខតំណែង ឯកឧត្តម **ម៉ែន គីមលី** ពីអគ្គលេខាធិការដ្ឋានរង នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ និង តែងតាំង ឯកឧត្តម **ច័ន្ទ សុខណ្ណារ៉ែត** ជំនួសវិញ ៩២១៦

៣០-៩-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៩១៣/៩៥០ ស្តីពី ការតែងតាំងលោកជំទាវ **អ៊ុំ សូម៉ានីន** ទីប្រឹក្សាអមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ មានឋានៈស្មើ រដ្ឋលេខាធិការ ៩២១៧

០១-១០-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៥១ ស្តីពី ការតែងតាំង និង តម្លើងឋានៈ ឯកឧត្តម ចំនួន ០២ រូប ជាទីប្រឹក្សាសម្តេចចៅហ្វាវាំង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ៩២១៨

០១-១០-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៥២ ស្តីពី ការតែងតាំង ឯកឧត្តម **ញឹក ប៊ុនឆៃ** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ ឧបនាយករដ្ឋមន្ត្រី ៩២១៩

០១-១០-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៥៣ ស្តីពី ការតែងតាំង ឯកឧត្តម **នុត ឈឿម** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ៩២២០

០១-១០-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៥៤ ស្តីពី ការតែងតាំង ឯកឧត្តម ចំនួន ០៥ រូប ជាទីប្រឹក្សារាជរដ្ឋាភិបាល ៩២២១

០១-១០-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៥៥ ស្តីពី ការបញ្ចប់មុខតំណែងទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សា-ជំនួយការទាំងអស់របស់ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី, ទីប្រឹក្សា-ជំនួយការទាំងអស់របស់ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី, ទីប្រឹក្សា-ជំនួយការទាំងអស់របសថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន និងទីប្រឹក្សា-ជំនួយការអមក្រសួង-ស្ថាប័នទាំងអស់ ដែលបានតែងតាំងមុនថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ៩២២២

០១-១០-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៥៦ ស្តីពី ការរំសាយឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និង ក្រុមប្រឹក្សាកំណែទម្រង់ពាក់ព័ន្ធផ្សេងទៀត ចំណុះឱ្យឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ៩២២៣

០១-១០-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៥៧ ស្តីពី ការលើកលែងទោសឱ្យទណ្ឌិតឈ្មោះ សាមិត្ត វីរៈ ហៅ ពេជ្រ ធឿន ៩២២៥

០៧-១០-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៥៨ ស្ដីពី ការតែងតាំង ឯកឧត្ដម ចំនួន ០៨ រូប ជាទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៩២២៦

០៧-១០-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៥៩ ស្ដីពី ការតែងតាំង ឯកឧត្ដម ស៊ឹម គុណគុសល ជាជំនួយការឯកឧត្ដម ម៉ម សារិន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ៩២២៧

០៧-១០-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៦០ ស្ដីពី ការតែងតាំង ឯកឧត្ដម តែ ឧត្ដម ជាជំនួយការឯកឧត្ដម ថោ សុខណ្ណ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ៩២២៨

០៧-១០-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៦១ ស្ដីពី ការតែងតាំង លោកជំទាវ សោម ច័ន្ទខស្សា ជាជំនួយការឯកឧត្ដម សោម សឿន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ៩២២៩

០៧-១០-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៦២ ស្ដីពី ការតែងតាំង ឯកឧត្ដម ស សំបូរធន ជាជំនួយការឯកឧត្ដម ហូ សិទ្ធី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ៩២៣០

០៧-១០-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៦៣ ស្ដីពី ការតែងតាំងទីប្រឹក្សា ជំនួយការ នាយក និងនាយករងខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការ គណៈរដ្ឋមន្ត្រី ចំនួន ០៥ រូប ៩២៣១

០៧-១០-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៦៤ ស្ដីពី ការតែងតាំង ទីប្រឹក្សា នាយក ខុទ្ទកាល័យ នាយករងខុទ្ទកាល័យ និងជំនួយការរបស់ឯកឧត្ដម យឹម ឆៃលី ឧបនាយក រដ្ឋមន្ត្រី ចំនួន ០៥ រូប ៩២៣២

០៧-១០-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៦៥ ស្ដីពី ការបញ្ចប់មុខតំណែងទីប្រឹក្សា ជំនួយការ នាយក នាយករងខុទ្ទកាល័យឯកឧត្ដម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានតែងតាំងមុនថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ និង តែងតាំង ទីប្រឹក្សា នាយក នាយករងខុទ្ទកាល័យឯកឧត្ដម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០៥ រូប ៩២៣៣

០៧-១០-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៦៦ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ឈិន ហ្វូមីង (CHEN FUMING) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តជីជាំង សាធារណរដ្ឋប្រជាមានិតចិន ដោយប្ដូរឈ្មោះជា ឈិន អ៊ុយមិញ (CHEN YU MING) ៩២៣៤

០៧-១០-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៦៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក រូដល់ហ្វឹស ខិលហិលមឹស ម៉ារីអា លូមីន (Rudolphus Wilhelmus Maria Looman) ជនជាតិហូឡង់ សញ្ជាតិហូឡង់ កើតនៅ Haarlem ប្រទេសហូឡង់ ៩២៣៥

០៧-១០-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៦៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី ចាង គីវហ្វាង (ZHANG QIUFAN) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តហេណាន សាធារណរដ្ឋប្រជាមានិតចិន ៩២៣៦

០៧-១០-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១០១៣/៩៦៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក វ៉ាង សាវប៉ (WANG SHAO BO) ជនជាតិហ្វីលីពីន សញ្ជាតិហ្វីលីពីន កើតនៅ ខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា វ៉ាង ជាយិន (WANG JIA REN) ៩២៣៧

## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២២-១០-២០១៣-អនុក្រឹត្យលេខ ៤៩០ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩២៣៨

២៤-១០-២០១៣-អនុក្រឹត្យលេខ ៤៩១ អនក្រ.បក ស្តីពី ការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ៩២៤០

០២-១០-២០១៣-អនុក្រឹត្យលេខ ៩៥០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២៤៤

០២-១០-២០១៣-អនុក្រឹត្យលេខ ៩៥១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២៤៦

០២-១០-២០១៣-អនុក្រឹត្យលេខ ៩៥២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២៤៧

០២-១០-២០១៣-អនុក្រឹត្យលេខ ៩៥៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២៤៨

០២-១០-២០១៣-អនុក្រឹត្យលេខ ៩៥៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២៤៩

០២-១០-២០១៣-អនុក្រឹត្យលេខ ៩៥៥ អនក្រ.តត ស្តីពី ការតែងតាំងទីប្រឹក្សាក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ៩២៥០

០២-១០-២០១៣-អនុក្រឹត្យលេខ ៩៥៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២៥១

០២-១០-២០១៣-អនុក្រឹត្យលេខ ៩៥៧ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៩២៥២

០២-១០-២០១៣-អនុក្រឹត្យលេខ ៩៥៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២៥៤

***-អនុក្រឹត្យលេខ ៩៥៩ អនក្រ.តត មិនទាន់បានទទួល***

០២-១០-២០១៣-អនុក្រឹត្យលេខ ៩៦០ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងជូននាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ៩២៥៥

០២-១០-២០១៣-អនុក្រឹត្យលេខ ៩៦១ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៩២៥៧

០២-១០-២០១៣-អនុក្រឹត្យលេខ ៩៦២ អនក្រ.តត ស្តីពី ការតែងតាំង និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៩២៥៩
០២-១០-២០១៣-អនុក្រឹត្យលេខ ៩៦៣ អនក្រ.តត ស្តីពី ការប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ ៩២៦០
០៧-១០-២០១៣-អនុក្រឹត្យលេខ ៩៦៤ អនក្រ.តត ស្តីពី ការកែសម្រួលសមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ៩២៦៨
០៧-១០-២០១៣-អនុក្រឹត្យលេខ ៩៦៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការស៊ីវិល ៩២៧១
០៧-១០-២០១៣-អនុក្រឹត្យលេខ ៩៦៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២៧២
០៧-១០-២០១៣-អនុក្រឹត្យលេខ ៩៦៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២៧៣
១៤-១០-២០១៣-អនុក្រឹត្យលេខ ៩៦៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២៧៤

## III~ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៨-៩-២០១៣ -ប្រកាសលេខ ៨០៨ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដេនីដ ខេម ប្លាស្ទិក អ៊ិនដាសស្ទ្រៀល បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ៩២៧៦
១៨-៩-២០១៣ -ប្រកាសលេខ ៨០៩ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គូដ មីរ៉ៃ ថយស៍ បង្កើតរោងចក្រ ផលិតតុក្កតា ៩២៨០
១៨-៩-២០១៣ -ប្រកាសលេខ ៨១០ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ភ័រហ្វិក គ្រោស៍ ប្រាយវេត ខូ អិលធីឌី បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៩២៨៤
១៨-៩-២០១៣ -ប្រកាសលេខ ៨១១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ញូ អីសសេន អ៊ិនធើណេសិនណល ហ្គាមេន លីមីធីត បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៩២៨៨

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៣/៩៨៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧២៥ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី ៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **ឯកឧត្តម ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **ម៉េង គីមលី** ពីអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ២** : តែងតាំង ឯកឧត្តម **ចំនួ សុវណ្ណារ៉េត** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ៣** : ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ និង សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ពរស. ១៧០៩.៩៦៣*

លេខៈ ៦៨៩ ស.ណ
**សំណៅចម្លងដែលមានភ្ជាប់ជាមួយការថែទាំផ្ទាល់**
**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ១៣ ឆ្នាំ២០១៣**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

*ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៣*

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៣/៩៥០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ក្រាស់បង្គាប់

តែងតាំង

លោកជំទាវ អ៊ុំ សូម៉ានីន

ជា

ទីប្រឹក្សាអមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
មានឋានៈស្មើ រដ្ឋលេខាធិការ

នរោត្តម សីហមុនី

នរោត្តម សីហមុនី

ពរស. ១៣០៩.៩៦៤
បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៣

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ០៥៨/១៣ ...រ.ធច
រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ តុលា ... ឆ្នាំ ២០១៣
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧត្តម គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៥១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

១- តែងតាំងឯកឧត្តម **អ៊ុក សុខុន** ជាទីប្រឹក្សា **សម្តេចចៅហ្វាវាំង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខតំណែងបច្ចុប្បន្ន។

២- តម្លើងឋានៈឯកឧត្តម **យី ធន់** ទីប្រឹក្សា **សម្តេចចៅហ្វាវាំង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ។

៣៖៧.១៣១០.៩៥៥

**បានប្រថាប់ព្រះរាជលញ្ឆករហើយ** **នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ០៥៥/១៣ រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

តែងតាំងឯកឧត្តម ញឹក ប៊ុនឆៃ ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ ឧបនាយករដ្ឋមន្ត្រី ។

**មាត្រា ២.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧៩៨. ១៧១០.៩៥៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០១៣

លេខៈ ៩៤៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ១០ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៥៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

តែងតាំងឯកឧត្តម នុត ឈឿម ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ។

**មាត្រា ២.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ:៩៥៧ស.ណ
សំណៅដែលមានឧត្តមធម៌ជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ១១ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

៣រស. ១៣១០.៩៥៧

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១.-**

តែងតាំងជាទីប្រឹក្សារាជរដ្ឋាភិបាល ចំនួន ០៥ រូប ៖

| | |
|---|---|
| ១- ឯកឧត្តម ទិត សុធា | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២- ឯកឧត្តម ញឹក វណ្ណាក់ | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ៣- ឯកឧត្តម លឹម រតនៈ | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ៤- ឯកឧត្តម រាជ សម្រេច | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ៥- ឯកឧត្តម អ៊ីស្មាឯល យូសុះ | មានឋានៈស្មើ រដ្ឋលេខាធិការ ។ |

**មាត្រា ២.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]. ១៣១០.៩៥៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៣

លេខៈ ៩៤៣ ស.ណ
**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៣**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៥៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** បញ្ចប់មុខតំណែងទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សា-ជំនួយការទាំងអស់របស់ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី, ទីប្រឹក្សា-ជំនួយការទាំងអស់របស់ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី, ទីប្រឹក្សា-ជំនួយការរបស់ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន និងទីប្រឹក្សា-ជំនួយការអមក្រសួង-ស្ថាប័នទាំងអស់ ដែលបានតែងតាំងដោយព្រះរាជក្រឹត្យមុនថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ។

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៨ស. ១៣១០.៩៦៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០១៣

លេខៈ ៩៤៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ១០ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៥៦

## ស្តីពី

## ការរំលាយឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និង ក្រុមប្រឹក្សាកំណែទម្រង់ចំណុះឱ្យឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានរំលាយឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និង ក្រុមប្រឹក្សាកំណែទម្រង់ពាក់ព័ន្ធផ្សេងទៀត ចំណុះឱ្យឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។

**មាត្រា ២.-**

ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និង ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការបង្កើតក្រុមប្រឹក្សាចំណុះឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋផ្សេងទៀត ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

ការងារកំណែទម្រង់រដ្ឋបាល ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងមុខងារសាធារណៈ ។

ការងារកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងយុត្តិធម៌ ។

ការងារកំណែទម្រង់កងយោធពលខេមរភូមិន្ទ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងការពារជាតិ ។

ការងារគោលនយោបាយដីធ្លី ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

**មាត្រា ៤.-**

ត្រូវបានផ្ទេរ និង ធ្វើសមាហរណកម្មអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ទៅក្នុងក្រសួងមុខងារសាធារណៈ ។

ត្រូវបានផ្ទេរ និង ធ្វើសមាហរណកម្មអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ទៅក្នុងក្រសួងយុត្តិធម៌ ។

**មាត្រា ៥.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកត.១០១៣.៩៧០

*ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣*

លេខៈ ៩៤៥ ស.ណ
**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ [illegible] ឆ្នាំ២០១៣**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានលើកលែងទោសឲ្យទណ្ឌិតឈ្មោះ សាមិត្ត វីរៈ ហៅ ពេជ្រ ធឿន ភេទប្រុស អាយុ ៤៨ឆ្នាំ ដែលត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ តាមអំណាចសាលដីកាលេខ ២៤ក្រ IVត ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ និងសាលដីកា លេខ ១៧១ ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៣ របស់តុលាការកំពូល។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រស. ១៣១០.៩៧១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣*

លេខ:៩៥៨ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៧ ខែ ១០ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** តែងតាំងជាទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន ០៨រូប ៖

| | |
|---|---|
| ១- ឯកឧត្តម ឈឹម កៃលាង | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ២- ឯកឧត្តម ម៉ម សុជាណា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៣- លោកជំទាវ យី ឆេង | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៤- ឯកឧត្តម សុខ សុនី | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៥- ឯកឧត្តម ណាក សាខន | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៦- ឯកឧត្តម ហេង វ៉ាន់ | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៧- ឯកឧត្តម លឹម ហោ | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៨- ឯកឧត្តម សាយ និដ្ឋា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |

**មាត្រា ២.-** និរាករណ៍ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩៣៨ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤.-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦៧.១៣១០.៩៧២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៣

លេខ: ៩៥០ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ១១ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៥៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/ ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំងឯកឧត្តម **ស៊ុម គុណកុសល** ជាជំនួយការឯកឧត្តម **ម៉ម សារិន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

ពរល.១៣១០.៩៧៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣

លេខៈ ៩៥៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៦០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំងឯកឧត្តម កែ ឧត្តម ជាជំនួយការឯកឧត្តម ង៉ោ សុវណ្ណ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៧រាល.១៣១០.៩៧៤

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣*

លេខ:៩៦០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ ខែ១០ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៦១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនត្តយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំងលោកជំទាវ **សោម ច័ន្ទសុទ្ធា** ជាជំនួយការឯកឧត្តម **សោម សឿន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧ រស. ១៧១០.៩៧៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣

លេខ: ៩៦១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ១០ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/ ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំងឯកឧត្តម **ស សំបូរធន** ជាជំនួយការឯកឧត្តម **ហូ សិទ្ធី** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រកព - ១៧១០.៩៧៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣

លេខៈ ៩៥៨ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** តែងតាំងទីប្រឹក្សា ជំនួយការ នាយក និងនាយករងខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ៖

| | | |
|---|---|---|
| ១-ឯកឧត្តម គីមឡៃ វិសិដ្ឋ | ជាទីប្រឹក្សានិងជានាយកខុទ្ទកាល័យ | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ២-ឯកឧត្តម យុត ចាន់ដារ៉ា | ជាទីប្រឹក្សានិងជានាយករងខុទ្ទកាល័យ | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៣-ឯកឧត្តម សឺង រេត | ជាទីប្រឹក្សា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៤-ឯកឧត្តម ម៉ៅ វិបុល | ជាទីប្រឹក្សា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៥-ឯកឧត្តម ហាក់ សុខហេង | ជាជំនួយការ | មានឋានៈស្មើ អគ្គនាយក។ |

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពនស. ១៣១០.៩៧៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៣*

លេខៈ ៦ ៤ ៩ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ១១ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៦៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនត្តយ៍ ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងទីប្រឹក្សា នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ និងជំនួយការរបស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ÷

១. ឯកឧត្តម **ជា សំណាង** ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២. ឯកឧត្តម **សំ សារ៉ាត** ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ ឋានៈស្មើ រដ្ឋលេខាធិការ
៣. ឯកឧត្តម **ទូច សារ៉េត** ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ ឋានៈស្មើ អនុរដ្ឋលេខាធិការ
៤. ឯកឧត្តម **ឡៅ សិទ្ធិ** ទីប្រឹក្សា ឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៥. ឯកឧត្តម **ហេង សិទ្ធី** ជំនួយការ ឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧.ស.១៣១០.៩៧៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៣

លេខៈ ៩៥៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ១០ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៦៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ចប់តំណែងទីប្រឹក្សា ជំនួយការ នាយក នាយករងខុទ្ទកាល័យឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលទទួលបានការតែងតាំងមុនថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ។

**មាត្រា ២ :** តែងតាំងទីប្រឹក្សា នាយក នាយករងខុទ្ទកាល័យឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ :

១-ឯកឧត្តម **អ៊ុយ ស៊ីម** ជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យ មានឋានៈស្មើ **រដ្ឋមន្ត្រី**

២-ឯកឧត្តម **ឯក មនោសែន** ជាទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ មានឋានៈស្មើ **រដ្ឋលេខាធិការ**

៣-ឯកឧត្តម **ឈឹម មង្គល** ជាទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ មានឋានៈស្មើ **រដ្ឋលេខាធិការ**

៤-ឯកឧត្តម **អ៊ឹម ថ្វន** ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

៥-ឯកឧត្តម **ឈាង កាន់ឌី** ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧១៧. ១៣១០. ៩៧៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៣

លេខៈ ៦៥៦ ស.ណ
**សំណៅដែលមានគម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ១០ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៦៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឈិន ហ្វូមីង** (CHEN FUMING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៦២ នៅខេត្តជឺជាំង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ឈិន អ៊ីមិញ** (CHEN YU MING)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧៣៦៣.១៣១០.៩៤០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៣

លេខ:៩៥៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ ខែ ១០ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៦៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **រូដល់ហ្វឺស វិលហែលមឹស ម៉ារីអា លូមែន** (Rudolphus Wilhelmus Maria Looman) ជនជាតិហូឡង់ សញ្ជាតិហូឡង់ កើតថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៦០ នៅ Haarlem ប្រទេសហូឡង់។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល. ១៣១០.៩៥១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៣

លេខៈ ៩៥៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ១០ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៦៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ចាង ឈីវហ្វាង** (ZHANG QIUFANG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៦៩ នៅខេត្តហេណាន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១៣១០.៩៥២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៣*

លេខៈ ៩៥៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៦៩

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **វ៉ាង សាវប៉** (WANG SHAO BO) ជនជាតិហ្វីលីពីន សញ្ជាតិហ្វីលីពីន កើតថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៩ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **វ៉ាង ជាយ៉េន** (WANG JIA REN)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាស.១៣១០.៩៤៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៣

លេខៈ៩៥៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៩០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ជូនក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ ÷

ឯកតា:លានរៀល

| ជំពូក | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | និយ័តកម្ម | | ឥណទានថ្មី |
|---|---|---|---|---|---|
| | | | កើន | ថយ | |
| ២១ | **និយ័តកម្មចេញ** | | | | |
| | ៩៩- ឥណទានមិនទាន់បែងចែក អចលកម្មរូបី | ៤០៥ ០០០ | | ១៨៤ ៣០០ | ២២០ ៧០០ |
| ២១ | **និយ័តកម្មចូល** | | | | |
| | ១៧- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ អចលកម្មរូបី | ២០ ០០០ | ៤ ៣០០ | | ២៤ ៣០០ |
| | ២០- ក្រសួងអភិវឌ្ឍន៍ជនបទ អចលកម្មរូបី | ១០០ ០០០ | ៨០ ០០០ | | ១៨០ ០០០ |
| | ២៥- ក្រសួងសាធារណការ និងដឹកជញ្ជូន អចលកម្មរូបី | ២០៥ ០០០ | ១០០ ០០០ | | ៣០៥ ០០០ |

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៧ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីគោរពជម្រាបជូន សម្តេចអគ្គមហាសេនាបតីតេជោ
នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩១ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/៩៥៦ ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរំសាយឧត្ដមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និងក្រុមប្រឹក្សាកំណែទម្រង់ចំណុះឱ្យឧត្ដមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើត "គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" ដើម្បីដឹកនាំការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្របតាមទិសដៅ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២.-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានបេសកកម្មដូចខាងក្រោម ៖

- សិក្សាស្រាវជ្រាវ និងរៀបចំផែនការយុទ្ធសាស្ត្រ ព្រមទាំងកម្មវិធីសកម្មភាពសម្រាប់ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្របតាមគោលនយោបាយ និងចក្ខុវិស័យនៃការកែទម្រង់របស់រាជរដ្ឋាភិបាល
- លើកសំណើជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច អំពីផែនការយុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាព ព្រមទាំងវិធានការចាំបាច់នានាដែលបម្រើឲ្យការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ ស្របតាមចក្ខុវិស័យកំណែទម្រង់របស់រាជរដ្ឋាភិបាល
- ជំរុញ និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលទទួលបានការអនុម័តពីរាជរដ្ឋាភិបាល
- ចេញសេចក្តីណែនាំចាំបាច់នានា ដល់គ្រប់ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធនឹងការអនុវត្តផែនការយុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពសម្រាប់ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- សម្របសម្រួលបណ្តាសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពសម្រាប់ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ដាក់ឲ្យដំណើរការនូវវិធានការចាំបាច់នានាសម្រាប់ការកែទម្រង់ប្រព័ន្ធតុលាការ បន្ទាប់ពីទទួលបានការឯកភាពពីរាជរដ្ឋាភិបាល
- ធ្វើទំនាក់ទំនង និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ ដើម្បីកៀរគរធនធានសម្រាប់ការអនុវត្តគម្រោងនានា ដែលបម្រើឱ្យការងារកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌
- ដាក់ឱ្យអនុវត្ត និងអភិវឌ្ឍនូវគម្រោងសាកល្បងនានា ដែលបម្រើឱ្យការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាអាទិ៍ គម្រោងតុលាការគំរូ គម្រោងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ផ្សព្វផ្សាយព័ត៌មាន ស្តីពីសកម្មភាព និងសមិទ្ធផលនានានៃការងារកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ ។

**មាត្រា ៣.-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | ជាប្រធាន |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ០១ រូប | ជាអនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | | ជាសមាជិក |
| - អនុប្រធានតុលាការកំពូល | ០១ រូប | ជាសមាជិក |
| - អគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការកំពូល | ០១ រូប | ជាសមាជិក |
| - ប្រធានសាលាឧទ្ធរណ៍ | | ជាសមាជិក |

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជាសមាជិក
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ០១ រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១ រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ០១ រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ០១ រូប ជាសមាជិក
- តំណាងអង្គភាពប្រឆាំងអំពើពុករលួយ ០១ រូប ជាសមាជិក
- ប្រធានលេខាធិការដ្ឋាន ជាសមាជិក

ការតែងតាំងសមាសភាពនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា ៤.-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បើកកិច្ចប្រជុំរបស់ខ្លួន តាមការអញ្ជើញរបស់ប្រធាន យ៉ាងតិច ១ ដង ក្នុង ១ ឆមាស។ ប្រធានអាចអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំ តាមការចាំបាច់។ ក្នុងករណីអវត្តមាន ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំបាន។

**មាត្រា ៥.-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ជាសេនាធិការ សម្រាប់គាំទ្រដំណើរការការងាររបស់ខ្លួន។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន តាមការចាំបាច់។ ប្រធាន និងអនុប្រធាន ព្រមទាំងសមាជិកនៃលេខាធិការដ្ឋានត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា ៦.-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ ដើម្បីដំណើរការការងាររបស់ខ្លួន។

**មាត្រា ៧.-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងយុត្តិធម៌។

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានសិទ្ធិទទួល និងគ្រប់គ្រងធនធានដែលបានមកពីប្រភពហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ។

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍនា**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៥០ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម ៖

១-លោកស្រី **អ៊ុច និពន្ធ** ជាជំនួយការ មានឋានៈស្មើ អគ្គនាយករង
២-លោក **ឆាំង ហ៊ុយ** ជាជំនួយការ មានឋានៈស្មើ អគ្គនាយករង
៣-លោក **ប៉េង ពោធិ៍នា** ជាជំនួយការ មានឋានៈស្មើ ប្រធាននាយកដ្ឋាន
៤-លោក **លី ស្មើ** ជាជំនួយការ មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

**មាត្រា ២.-**

បទប្បញ្ញត្តទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៩៥១ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឯកឧត្តម **សោម សឿន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

តែងតាំងឥស្សរជនចំនួន ០៣ រូប ជាជំនួយការឯកឧត្តម **សោម សឿន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដូចមានខាងក្រោមៈ

១- លោកស្រី ចាន់ ពិសី មានឋានៈស្មើ អគ្គនាយករង
២- លោក ចាន់ សុខសាន្ត មានឋានៈស្មើ ប្រធាននាយកដ្ឋាន
៣- លោកស្រី គង់ ស្រីពៅ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឯកឧត្តម **ហ្វូ សិទ្ធី** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

**ស ម្រេ ច**

**មាត្រា ១.-**

តែងតាំងឥស្សរជនចំនួន ០៣ រូប ជាជំនួយការឯកឧត្តម **ហ្វូ សិទ្ធី** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដូចមានខាងក្រោម៖

១. លោក ហាយ កុសល មានឋានៈស្មើ អគ្គនាយករង
២. លោក ពៅ ជីវៈមតា មានឋានៈស្មើ ប្រធាននាយកដ្ឋាន
៣. លោក ស្រ៊ិញ វីរៈជាតិ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៥៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឯកឧត្តម ង៉ោ សុវណ្ណ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

តែងតាំងឥស្សរជនចំនួន ០៣ រូប ជាជំនួយការឯកឧត្តម ង៉ោ សុវណ្ណ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដូចមានខាងក្រោម៖

១- លោក ថេង ជាង មានឋានៈស្មើ អគ្គនាយករង

២- លោក យិន សុខម៉ៅ មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៣- លោក ហុក សុវណ្ណា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៥៤ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឯកឧត្តម **ម៉ម សារិន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

**សម្រេច**

**មាត្រា ១.-**

តែងតាំងឥស្សរជនចំនួន ០៣ រូប ជាជំនួយការឯកឧត្តម **ម៉ម សារិន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដូចមានខាងក្រោម៖

១- លោកស្រី ឡេង ផលលាភី មានឋានៈស្មើ អគ្គនាយករង

២- លោក ញ៉ែម សុខជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៣- លោក ថាន់ ពៅ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១.-** តែងតាំងលោក ហ៊ុល គីមហេង ជាទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៩៥៦...អនក្រ.តតក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **ឡាំ សំខាន់** ឋានន្តរសក្តិ វិរមន្ត្រី ថ្នាក់លេខ ៦ ជា **អភិបាល** នៃគណៈអភិបាលខណ្ឌចំការមន រាជធានីភ្នំពេញ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ១០ ឆ្នាំ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចលោក **ម៉ៅ អៀង** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ៦ ពីអភិបាលស្រុកបាភ្នំ នៃខេត្តព្រៃវែង ឱ្យមកបម្រើការងារជាទីប្រឹក្សាក្រសួងមហាផ្ទៃ ឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២ :** តែងតាំងលោក **ឆេត តារុន** ឋាននន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ១០ ជាអភិបាលស្រុកបាភ្នំ នៃខេត្តព្រៃវែង ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៥៨ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៥ អនក្រ.បក ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា។
- យោងតាមសំណើរបស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងជំនួយការរបស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម÷

១. លោក **ចំនួធី សុជីវ៉ា** ជំនួយការ ឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន

២. លោក **ភាន់ សុទ្ធី** ជំនួយការ ឋានៈស្មើ អគ្គនាយករង

៣. លោកវេជ្ជ. **មុំ និត្យទិវិរុន្ទ្រ** ជំនួយការ ឋានៈស្មើ ប្រធាននាយកដ្ឋាន

៤. លោក **ឯម ចំនួទិទឡ្ស៍** ជំនួយការ ឋានៈស្មើ ប្រធាននាយកដ្ឋាន

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៩៧០ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែងជូននាយនគរបាលថ្នាក់ឧត្តមសេនីយ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំងមុខតំណែងជូននាយនគរបាលថ្នាក់ឧត្តមសេនីយ៍នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ដូចខាងក្រោម ៖

១-លោកឧត្តមសេនីយ៍ទោ ចៅ ឥត្ថិ អត្តលេខ ៥៤៨៦២ ជា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ដោយបន្ថែមលើមុខងារបច្ចុប្បន្ន

២-លោកឧត្តមសេនីយ៍ត្រី ម៉ៅ យូណៃល អត្តលេខ ៥៤៨៦៣ ជា ប្រធាននាយកដ្ឋានស្រាវជ្រាវឧបករណ៍សម្ភារៈបច្ចេកទេសនគរបាល នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ។

/ៅ

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៣
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៩៧១.អនក្រ-បក**

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចមន្ត្រីរាជការនៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ដូចខាងក្រោម ៖

១-ឯកឧត្តម សុខ សារិទ្ធ ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ២ ពី អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ទៅជា អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ

២-លោក ទិន បុណ្ណារ៉ា ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ១០ ពី អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ទៅជា អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ [illegible] ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ៣*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំង និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា ១.-**

តែងតាំងលោកស្រី ជូ ពុទ្ធានី ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ នៃក្រសួងផែនការ ។

**មាត្រា ២.-**

ប្រគល់ភារកិច្ចជូនលោក កែវ អ៊ួលី ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានផែនការ សង្គមកិច្ច នៃអគ្គនាយកដ្ឋានផែនការ នៃក្រសួងផែនការ ជំនួសលោកស្រី ជូ ពុទ្ធានី ដែលត្រូវបានទទួលភារកិច្ចថ្មី ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៩៦៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា ១.-**

ប្តូរប្រភេទក្របខ័ណ្ឌតាមលទ្ធផលប្រឡងប្រជែងផ្ទៃក្នុង ជូនមន្ត្រីរាជការ ចំនួន ១៨៥ នាក់ ទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ នៅក្រសួងផែនការ មានដូចខាងក្រោម ៖

| ល.រ | គោត្តនាម និង នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | ឋានន្តរស័ក្តិ | ថ្នាក់ |
|---|---|---|---|---|---|
| ១ | **ខុន ច័ន្ទវត្តី** | ស្រី | ០៧/០៦/១៩៧៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ២ | **យ៉ែម សាឃឿន** | ស្រី | ០២/០៤/១៩៦៦ | ក្រមការ | ថ្នាក់លេខ ១៤ |

| | | | | | |
|---|---|---|---|---|---|
| ៣ | ចាន់ សុផល | ប្រុស | ០៥/១២/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៤ | សៀង សុខាន់ | ស្រី | ១៦/០៨/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៥ | ម៉ា ស្រីភា | ស្រី | ១២/០៦/១៩៧៤ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៦ | ស៊ីសុវត្ថិ សត្យា | ស្រី | ០១/០៩/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៧ | ប៊ិច ហួត | ប្រុស | ០៨/១០/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៨ | សំ ចាន់ធី | ស្រី | ០១/០៣/១៩៦៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៩ | លីន មុន្នីរត្ន | ស្រី | ០៣/១២/១៩៧៥ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១០ | សេង រ៉ាឌី | ប្រុស | ០១/០១/១៩៦៦ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១១ | អ៊ុន ចន្ធី | ប្រុស | ០៩/១០/១៩៥៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១២ | កៅ ស្រីអួន | ស្រី | ១២/១២/១៩៨៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៣ | ប៉ុក សុខេម | ស្រី | ០២/១១/១៩៧៤ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៤ | ស្វាយ ផាត | ប្រុស | ០២/០៥/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៥ | ម៉ាក ស៊ីថា | ស្រី | ១៨/០៥/១៩៧៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៦ | ប៊ិះ សាវរី | ប្រុស | ១៥/០៤/១៩៧២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៧ | លី ហួរ | ប្រុស | ២០/១០/១៩៧១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៨ | ប្រាជ្ញ ទេពចារ៉ាក់ | ស្រី | ២៦/១១/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៩ | ពុំ សោមម៉ារី | ស្រី | ០១/០៤/១៩៧២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ២០ | នុប សុគន្ធារី | ស្រី | ២៦/០២/១៩៧៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ២១ | ខៀវ ចន្ថា | ប្រុស | ០៧/០១/១៩៦៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ២២ | យក់ សំវត្តី | ស្រី | ១០/១១/១៩៧៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ២៣ | ហ៊ី គីមគ្រី | ប្រុស | ១០/១០/១៩៧២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ២៤ | មិន សាម៉េត | ប្រុស | ០៤/០៧/១៩៨០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ២៥ | មិន ខឿន | ប្រុស | ០៥/០៧/១៩៦៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ២៦ | ហេង ម៉ាឡា | ស្រី | ០១/០១/១៩៦៦ | ក្រមការ | ថ្នាក់លេខ ១៤ |
| ២៧ | ជិន អ៊ូច | ប្រុស | ០៣/០៧/១៩៧៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ២៨ | ខុន ណារ៉ែន | ស្រី | ២៦/១១/១៩៨០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ២៩ | ផន សុខា | ស្រី | ០៦/០២/១៩៨២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៣០ | ម៉ៅ សារ៉ែន | ប្រុស | ០២/០៦/១៩៦១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៣១ | មូល សុគន្ធ | ប្រុស | ០៧/១០/១៩៧៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៣២ | ស៊ឹង គា | ប្រុស | ២៦/០៤/១៩៧៤ | ក្រមការ | ថ្នាក់លេខ ១៤ |

| | | | | | |
|---|---|---|---|---|---|
| ៣៣ | ជុំ រមនា | ស្រី | ០៥/០១/១៩៦៦ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៣៤ | ចន្ទា កុសល | ប្រុស | ១២/០៦/១៩៧២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៣៥ | អ៊ុក មរកត | ស្រី | ០៣/០៨/១៩៧២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៣៦ | ជា ណារុន | ស្រី | ០២/០៨/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៣៧ | នុត ស្រីទូច | ស្រី | ១៥/១២/១៩៧១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៣៨ | គង់ ស្រីនី | ស្រី | ០៤/០៣/១៩៧១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៣៩ | សាមុត្ត សុទ្ធថា | ប្រុស | ២៥/០៣/១៩៧៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៤០ | ញ៉ែម ស្រី | ស្រី | ១២/១០/១៩៧៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៤១ | រុន សុចន្ទា | ស្រី | ១៦/០៧/១៩៧១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៤២ | ម៉ាក ផល | ប្រុស | ០៦/០៥/១៩៧៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៤៣ | សាន សុធឿន | ប្រុស | ២៥/១១/១៩៦៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៤៤ | ថេង សុធា | ស្រី | ០៥/១១/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៤៥ | ហេង ចិសាល | ប្រុស | ០១/០១/១៩៦៦ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៤៦ | គិន ណៃលា | ស្រី | ១២/១០/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៤៧ | គួយ សុភាព | ប្រុស | ៣១/០៥/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៤៨ | សាន សំអុល | ប្រុស | ០៧/០៤/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៤៩ | ឡាយ សុផល | ប្រុស | ០១/០៦/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៥០ | សេង ចន្ធី | ប្រុស | ០៥/០៣/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៥១ | ឌិ សាវី | ស្រី | ១៣/០៤/១៩៦៤ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៥២ | រ័ត្ន ស៊ីណាត | ប្រុស | ០១/០១/១៩៧៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៥៣ | ប្រាក់ សុផាត | ប្រុស | ០៤/១២/១៩៦៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៥៤ | ស៊ីន ចន្ធា | ប្រុស | ១១/១១/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៥៥ | សុត សត្យា | ប្រុស | ១០/១០/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៥៦ | យ៉ុន និមល | ប្រុស | ១០/០៥/១៩៦៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៥៧ | ចែម សុផល | ស្រី | ១០/១០/១៩៦៤ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៥៨ | សំរិត សាម៉ុន | ប្រុស | ១០/០១/១៩៦៦ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៥៩ | រស់ រឿន | ប្រុស | ១៥/១២/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៦០ | ទិន ប៊ុនធឿន | ប្រុស | ០៦/០៤/១៩៦២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៦១ | ជុំ អឿន | ប្រុស | ០៥/០៥/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៦២ | វ៉ាន់ សុបាន | ប្រុស | ១៥/០៧/១៩៧១ | ក្រមការ | ថ្នាក់លេខ ១៤ |

| | | | | | |
|---|---|---|---|---|---|
| ៦៣ | កែវ ទិធាវី | ស្រី | ១១/០៧/១៩៦៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៦៤ | សុខ ចរិយា | ប្រុស | ០៥/០៩/១៩៧៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៦៥ | អឹម ធីយុទ្ធា | ប្រុស | ០៧/១២/១៩៦០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៦៦ | ស៊ុម សំអុល | ប្រុស | ១២/០៨/១៩៧១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៦៧ | អេង សុផល | ប្រុស | ១០/១០/១៩៦៤ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៦៨ | ឃឹម សុភារុន | ប្រុស | ០៣/០៤/១៩៧០ | ក្រមការ | ថ្នាក់លេខ ៨ |
| ៦៩ | ខឿ វ៉ាន់ថាច | ប្រុស | ០១/០១/១៩៦១ | ក្រមការ | ថ្នាក់លេខ ៨ |
| ៧០ | ឈុំ គឹមសាន | ប្រុស | ២៩/០១/១៩៦៩ | ក្រមការ | ថ្នាក់លេខ ៩ |
| ៧១ | នៅ លាបផេង | ប្រុស | ០៧/០៩/១៩៦៤ | ក្រមការ | ថ្នាក់លេខ ៩ |
| ៧២ | អ៊ូ ឆេងឡុច | ប្រុស | ១៤/០៨/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៧៣ | ឌុច ហុងលី | ប្រុស | ២៤/០៧/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៧៤ | ស្រេង សុផា | ស្រី | ១២/០៤/១៩៧២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៧៥ | យូ សុខអាន | ប្រុស | ០៣/០៤/១៩៦៦ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៧៦ | ផាន់ ណារ៉ា | ស្រី | ១៨/០៨/១៩៦៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៧៧ | ហ៊ី ចាន់ធី | ប្រុស | ០២/០៥/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៧៨ | ហាន ខឿន | ប្រុស | ០៥/០១/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៧៩ | ញ៉ឹក គឹមយ៉ុង | ប្រុស | ០៧/០៩/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៨០ | ស៊ុំ តឹក | ប្រុស | ០៣/០៩/១៩៦៦ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៨១ | ម៉ឹង គឹមជី | ប្រុស | ១១/១១/១៩៦៥ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៨២ | លឹម ហួង | ប្រុស | ០៥/០៦/១៩៦៤ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៨៣ | សោម យ៉ុត | ប្រុស | ០២/០១/១៩៦៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៨៤ | លឹម លក្ខិណា | ស្រី | ៣០/១១/១៩៧២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៨៥ | អ៊ុក រ័ត្នធីតា | ស្រី | ១០/០៤/១៩៦៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៨៦ | មាស ចន្ទី | ប្រុស | ២៥/០៥/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៨៧ | សៀន សុខុន | ស្រី | ០២/០៥/១៩៧៤ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៨៨ | រស់ សុភាព | ស្រី | ១៨/១២/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៨៩ | គង់ សុខតិ្ត | ប្រុស | ០៩/០៩/១៩៧២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៩០ | ឡេង ព្រីង | ប្រុស | ០៩/០៥/១៩៧១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៩១ | ហូ សារស់ | ប្រុស | ៣០/០១/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៩២ | សេង ម៉ូណា | ប្រុស | ១៤/០៧/១៩៧២ | ក្រមការ | ថ្នាក់លេខ ១៤ |

| | | | | | |
|---|---|---|---|---|---|
| ៩៣ | យូ ប៉ោអាន | ប្រុស | ០១/០៤/១៩៧០ | ក្រមការ | ថ្នាក់លេខ ៧ |
| ៩៤ | អ៊ូច ស៊ាន | ប្រុស | ១៣/០៧/១៩៦២ | ក្រមការ | ថ្នាក់លេខ ៩ |
| ៩៥ | អៀង សុផាត | ប្រុស | ១២/០៨/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៩៦ | ឡាយ បុរិន្ទ | ប្រុស | ០១/០១/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៩៧ | ម៉ុន សុផល | ស្រី | ១០/០៣/១៩៧១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៩៨ | អ៊ួន សំបូរ | ប្រុស | ០៥/០២/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ៩៩ | នួន ញ៉ាំ | ប្រុស | ០៤/០៩/១៩៦៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១០០ | គង់ ស៊ុយ | ប្រុស | ១០/០១/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១០១ | សៅ ព្រំវុទ្ធី | ប្រុស | ០២/០២/១៩៧៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១០២ | មិន សាររដ្ឋ | ប្រុស | ១២/០៦/១៩៦៨ | ក្រមការ | ថ្នាក់លេខ ៨ |
| ១០៣ | ប្រាក់ ឡី | ប្រុស | ១៩/១០/១៩៦៧ | ក្រមការ | ថ្នាក់លេខ ៨ |
| ១០៤ | ស្ដើង គីរី | ស្រី | ០១/០៩/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១០ |
| ១០៥ | ញ៉ឹប ឈៀង | ប្រុស | ១៥/០៣/១៩៧៦ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១០៦ | អ៊ុក ស្រស់ | ប្រុស | ០៣/១២/១៩៨០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១០៧ | សោម ប៊ុណ្ណារី | ស្រី | ០១/០១/១៩៦១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១០៨ | សំ តុលា | ប្រុស | ២២/១០/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១០៩ | សំ ឡាយ | ប្រុស | ០៩/០៩/១៩៦៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១១០ | សឹម ពុទ្ធី | ប្រុស | ១៧/១០/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១១១ | សុខ វិបុល | ប្រុស | ២៥/០៤/១៩៧៤ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១១២ | អ៊ុក សុម៉ាអ៊ី | ស្រី | ១២/១២/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១១៣ | ឡុង សុខា | ប្រុស | ១៧/០៨/១៩៦៥ | ក្រមការ | ថ្នាក់លេខ ៨ |
| ១១៤ | ម៉ែន ម៉ាច | ប្រុស | ១០/០៣/១៩៧៣ | ក្រមការ | ថ្នាក់លេខ ៨ |
| ១១៥ | ឈឹម ឈៀង | ប្រុស | ០៦/០៦/១៩៦៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១១៦ | ឈឹម សុហាត | ប្រុស | ០៥/០៨/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១១៧ | នួន ស៊ីថុន | ស្រី | ១៥/០១/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១១៨ | សួម ហេន | ប្រុស | ០៥/០៩/១៩៥៨ | ក្រមការ | ថ្នាក់លេខ ៧ |
| ១១៩ | ពីន សុភ័ណ្ឌ | ប្រុស | ១៥/០៣/១៩៧២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១២០ | អ៊ិក វណ្ណា | ប្រុស | ១០/០៩/១៩៧៥ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១២១ | តូច សុខា | ប្រុស | ០៥/០៧/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១២២ | ហួត ស៊ីណាត | ស្រី | ០៦/០១/១៩៥៩ | ក្រមការ | ថ្នាក់លេខ ១៤ |

| | | | | | |
|---|---|---|---|---|---|
| ១២៣ | សែម សុភា | ស្រី | ១៥/១០/១៩៥៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១២៤ | ខឹម សុផាត | ប្រុស | ០៩/០៥/១៩៧៤ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១២៥ | ហ៊ូ សាវ៉ាត | ប្រុស | ០១/០១/១៩៦៣ | ក្រមការ | ថ្នាក់លេខ ៩ |
| ១២៦ | ស៊ាប សាន | ប្រុស | ១០/១២/១៩៦៧ | ក្រមការ | ថ្នាក់លេខ ៩ |
| ១២៧ | អ៊ាន ខឿន | ប្រុស | ០៥/១២/១៩៦៩ | ក្រមការ | ថ្នាក់លេខ ៩ |
| ១២៨ | តាន់ សុភ័ក្ត្រ | ប្រុស | ១១/០៦/១៩៦៩ | ក្រមការ | ថ្នាក់លេខ ៩ |
| ១២៩ | ហោ គិមអាយ | ស្រី | ១៩/១១/១៩៦៧ | ក្រមការ | ថ្នាក់លេខ ៩ |
| ១៣០ | ឈិវ សាល | ប្រុស | ០៥/០៨/១៩៦៩ | ក្រមការ | ថ្នាក់លេខ ៩ |
| ១៣១ | ឈឿន សុភោ | ប្រុស | ០៦/០៦/១៩៦៨ | ក្រមការ | ថ្នាក់លេខ ៩ |
| ១៣២ | សរ ពុទ្ធាវី | ស្រី | ០១/១២/១៩៧៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៣៣ | រី រ៉ែន | ប្រុស | ០១/០៧/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៣៤ | ទូច ផាន់ណា | ស្រី | ២០/០៦/១៩៦៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៣៥ | សោម សុខឿន | ស្រី | ០៥/០៤/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៣៦ | ឡុង លក្ខណា | ស្រី | ០៥/១០/១៩៦៧ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៣៧ | ដួង សាម៉ុន | ប្រុស | ១៦/០៦/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៣៨ | ជា ណារិន | ប្រុស | ០៥/០៥/១៩៦៦ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៣៩ | ស៊ុយ មូរ៉ា | ប្រុស | ៣០/១២/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៤០ | រុន ណារ៉ែត | ប្រុស | ១០/០២/១៩៧១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៤១ | ឡៅ គិមឈាក | ប្រុស | ១០/០៥/១៩៦៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៤២ | លួង សេរី | ប្រុស | ០៣/០៧/១៩៧៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៤៣ | សយ សារុន | ប្រុស | ០៧/១០/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៤៤ | ឡុច វ៉ាន់ឌី | ស្រី | ០៥/០៣/១៩៨៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៤៥ | យ៉េង ចាន់ធុន | ស្រី | ០១/០៨/១៩៨១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៤៦ | ចាប សំណាង | ប្រុស | ២០/០១/១៩៨២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៤៧ | ជា ឈុនឡឿន | ប្រុស | ១០/០១/១៩៨៥ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៤៨ | យ៉ត វឌ្ឍមុនីរ័ត្ន | ប្រុស | ២៥/០១/១៩៨២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៤៩ | ផុន ចាន់និល | ប្រុស | ១៨/០៩/១៩៨៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៥០ | ភួន ចំរ៉ាន | ស្រី | ២០/០២/១៩៨២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៥១ | លេន សុវណ្ណា | ប្រុស | ០៨/០៩/១៩៨៦ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៥២ | ឈាន សុធា | ប្រុស | ០២/០៣/១៩៨៩ | ក្រមការ | ថ្នាក់លេខ ១៤ |

| | | | | | |
|---|---|---|---|---|---|
| ១៥៣ | ជា ចន្ថរ្យនា | ប្រុស | ០៥/០៥/១៩៨៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៥៤ | ស៊ាន សុគីន | ស្រី | ០២/០៩/១៩៧៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៥៥ | កែវ គន្ធារូន | ស្រី | ២៤/១០/១៩៧៤ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៥៦ | ទិន ស្រីមុំ | ស្រី | ២៦/០៦/១៩៨៤ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៥៧ | អ៊ែង សេងហាន | ប្រុស | ០៤/០៤/១៩៧៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៥៨ | សន សុខុន | ប្រុស | ០៥/១០/១៩៥៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៥៩ | ចាន់ ប៉ែត | ប្រុស | ១៦/១២/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៦០ | ទង់ បូផាវី | ស្រី | ១៥/០៣/១៩៦៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៦១ | សឿង វ៉ាន | ប្រុស | ០៨/០៨/១៩៦៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៦២ | សេង ឡាំ | ប្រុស | ១៥/០២/១៩៧៤ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៦៣ | គឿន ចន្ទី | ប្រុស | ១៦/០៦/១៩៨៥ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៦៤ | ជី ផល្លា | ប្រុស | ១០/១១/១៩៧៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៦៥ | យ៉េត អូន | ប្រុស | ០៩/០២/១៩៦៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៦៦ | ចាន់ សុផល | ស្រី | ០៧/០៧/១៩៨១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៦៧ | ខែម សុភាព | ស្រី | ០៧/០៧/១៩៨២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៦៨ | មុំ សុធីដា | ស្រី | ០៤/០២/១៩៨១ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៦៩ | ឆាយា ឆដា | ប្រុស | ២៩/០៤/១៩៨៣ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៧០ | ខាំ ឧត្តម | ប្រុស | ០៩/០៤/១៩៨៨ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៧១ | ឃួន គឿន | ប្រុស | ០៧/១២/១៩៦៤ | ក្រមការ | ថ្នាក់លេខ ៧ |
| ១៧២ | គង់ សាលី | ប្រុស | ១៣/០២/១៩៦៧ | ក្រមការ | ថ្នាក់លេខ ៧ |
| ១៧៣ | ហាស់ សាបាន | ប្រុស | ១៧/០៣/១៩៥៩ | ក្រមការ | ថ្នាក់លេខ ១៣ |
| ១៧៤ | ម៉ុក សុវណ្ណា | ប្រុស | ១០/០២/១៩៦៦ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៧៥ | អ៊ុក សុវណ្ណានី | ស្រី | ០៧/០១/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៧៦ | ភាស ម៉ាច | ស្រី | ០៤/១១/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៧៧ | ថោង កុម្ភៈ | ប្រុស | ០២/០២/១៩៨៥ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៧៨ | ឈឹម រតនៈ | ស្រី | ០៤/១២/១៩៧០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៧៩ | មាស សារឹម | ប្រុស | ០៥/០២/១៩៦២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៨០ | គីម ប៊ុណ្ណា | ប្រុស | ០៥/១១/១៩៥៩ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៨១ | សោម សាផុន | ប្រុស | ០៥/១០/១៩៦៥ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៨២ | អ៊ូ ផាវី | ស្រី | ០៧/០១/១៩៦៨ | ក្រមការ | ថ្នាក់លេខ ១៤ |

| | | | | | |
|---|---|---|---|---|---|
| ១៨៣ | **ជា សាផុន** | ប្រុស | ១៥/០៥/១៩៦០ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៨៤ | **កែ គា** | ប្រុស | ១៣/១០/១៩៦២ | ក្រមការ | ថ្នាក់លេខ ១៤ |
| ១៨៥ | **ឱត្យ សាគួន** | ប្រុស | ១៣/០៤/១៩៦៥ | ក្រមការ | ថ្នាក់លេខ ១៤ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៦៤.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលសមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១១/៩៤១ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- យោងតាមតម្រូវការចាំបាច់របស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

## សម្រេច

**មាត្រា ១ :** ត្រូវបានកែសម្រួលសមាសភាពអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដែលមានរាយនាមដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ប៊ិន ឈិន | ឧបនាយករដ្ឋមន្ត្រី | ប្រធាន |
| ២- | ឯកឧត្តម អ៊ឹម ឈុនលឹម | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធានទី១ |
| ៣- | ឯកឧត្តម យុន ហាំង | ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស | អនុប្រធានប្រចាំការ |

| | | | |
|---|---|---|---|
